ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
អគ្គនាយកដ្ឋានយោធសេវា
នាយកដ្ឋានព័ត៌មាន
លេខ:.................

# សេចក្តីប្រកាសព័ត៌មាន

តបតាមការអញ្ជើញរបស់ សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ ឯកឧត្តម នាយឧត្តមសេនីយ៍ វ៉ៃ ហ្វេនហេ WEI FENGHE សមាជិកក្រុមប្រឹក្សារដ្ឋ និងជារដ្ឋមន្ត្រីក្រសួងការពារប្រទេស នៃសាធារណរដ្ឋប្រជាមានិតចិន នឹងដឹកនាំគណៈប្រតិភូអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃទី១៦ ដល់ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨ ។

ក្នុងឱកាសដំណើរបំពេញទស្សនកិច្ចនេះ ឯកឧត្តម នាយឧត្តមសេនីយ៍ វ៉ៃ ហ្វេនហេ នឹងដឹកនាំគណៈប្រតិភូចូលជួបសម្តែងការគួរសមចំពោះ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅវិមានសន្តិភាព ទីស្តីការនាយករដ្ឋមន្ត្រី ។

គណៈប្រតិភូក្រសួងការពារប្រទេសចិន ដឹកនាំដោយឯកឧត្តម នាយឧត្តមសេនីយ៍ វ៉ៃ ហ្វេនហេ នឹងចូលជួបពិភាក្សាការងារជាមួយ សម្តេចពិជ័យសេនា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ ។ នៅក្នុងជំនួបពិភាក្សានេះ ក៏មានរៀបចំពិធីចុះហត្ថលេខា កិច្ចសហប្រតិបត្តិការរវាងក្រសួងការពារប្រទេសទាំងពីរ **កម្ពុជា-ចិន** ក្រោមអធិបតីភាព សម្តេចពិជ័យសេនា ទៀ បាញ់ និងឯកឧត្តម នាយឧត្តមសេនីយ៍វ៉ៃ ហ្វេនហេ នៅអគារមិត្តភាព ទីស្តីការគណៈរដ្ឋមន្ត្រី ។

ក្នុងអំឡុងពេលស្នាក់នៅព្រះរាជាណាចក្រកម្ពុជា ឯកឧត្តម នាយឧត្តមសេនីយ៍ វ៉ៃ ហ្វេនហេ ព្រមទាំងគណៈប្រតិភូ នឹងអញ្ជើញចូលរួមក្នុងពិធីបើកសម្ពោធពិព័រណ៍យោធារួមគ្នា **កម្ពុជា-ចិន** ក្រោមអធិបតីភាពរដ្ឋមន្ត្រីក្រសួងការពារជាតិ នៃប្រទេសទាំងពីរ នៅមជ្ឈមណ្ឌលពាណិជ្ជកម្មពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញផងដែរ ៕

ថ្ងៃព្រហស្បតិ៍ ២កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០១៨